១

# បុចិមន្ទជាតក



ដើមស្ដៅ

*ព្រះសាស្ដា កាលស្ដេចគង់នៅវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះមហាមោគ្គល្លានដ៏មានអាយុ បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **ឧដ្ឋេហិ ចោរ** *ដូច្នេះជាដើម ។*

*បានឮមកថា កាលព្រះថេរៈស្នាក់នៅកុដិក្នុងព្រៃ ដែលអាស្រ័យនឹងក្រុងរាជគ្រឹះ មានចោរម្នាក់កាត់ទីតក្នុងផ្ទះមួយ ក្នុងស្រុកទៀបទ្វារនគរ កាន់យក***ហត្ថសារៈ** *រត់ចូលទៅបរិវេណកុដិរបស់ព្រះថេរៈ ដេកនៅមុខបណ្ណសាលារបស់ព្រះថេរៈ ដោយគិតថា ការរក្សាការពារនឹងមានដល់អញ ក្នុងទីនេះ ។*

*ព្រះថេរៈដឹងភាពដែលចោរនោះ ដេកនៅខាងមុខ ធ្វើសេចក្ដីរង្កៀសចំពោះចោរនោះ លោកគិតថា «ធម្មតាការស្និទ្ធស្នាលនឹងចោរ មិនគួរទេ» លោកក៏ចេញមកបណ្ដេញថា «អ្នកកុំដេកនៅទីនេះ» ។ ចោរនោះចេញពីទីនោះ រត់បង្វែងដាន ។ មនុស្សទាំងឡាយកាន់គប់ភ្លើង មកដល់ទីនោះ ដោយស្នាមជើងចោរ ឃើញទីមក ទីឈរ ទីអង្គុយ និង*

ទីដេកជាដើម ក៏នាំគ្នានិយាយថា «ចោរមកពីទីនេះ ឈរទីនេះ អង្គុយទីនេះ គេចទៅតាមផ្លូវនេះ យើងលែងឃើញហើយ» ក៏នាំគ្នារត់ទៅទីនេះផងនោះផង នៅតែមិនឃើញ ទើបត្រឡប់ទៅវិញ ។ ក្នុងថ្ងៃស្អែក វេលាបុព្វណ្ហសម័យ ព្រះថេរៈនិមន្តត្រាច់ទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ពេលត្រឡប់ពីបិណ្ឌបាតវិញ លោកនិមន្តទៅវត្តវេឡុវ័ន ក្រាបទូលការប្រព្រឹត្តទៅនោះចំពោះព្រះសាស្តា ។ ព្រះសាស្តាត្រាស់ថា «ម្នាលមោគ្គល្លាន មិនមែនតែអ្នកទេ ដែលរង្កៀសចំពោះហេតុដែលគួររង្កៀស សូម្បីបោរាណបណ្ឌិតទាំងឡាយក៏ធ្លាប់រង្កៀសដែរ» ដូច្នេះហើយ កាលព្រះថេរៈអារាធនា ទ្រង់បាននាំ អតីតនិទានមកសម្តែងថា ៖

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តបានសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វបានកើតជា**និម្ពរុក្ខទេវតា** (ទេវតាដើមស្តៅ) ក្នុងព្រៃស្មសាននៃព្រះនគរ ។ ថ្ងៃមួយ ចោរម្នាក់បានធ្វើអំពើលួចក្នុងស្រុកជិតទ្វារនគរ ហើយបានរត់ចូលក្នុងព្រៃស្មសាននោះ ។ គ្រានោះ មានដើមឈើជាចម្បង ២ គឺ **និម្ពព្រឹក្ស** (ដើមស្តៅ) ១ **អស្សត្ថព្រឹក្ស** (ដើមពោធិ៍) ១ ដុះក្នុងព្រៃនោះ ។ ចោរបានដាក់បង្វេចទ្រព្យក្បែរគល់និម្ពព្រឹក្សហើយដេក ។ ក្នុងកាលនោះ ពួកមនុស្សចាប់ចោរទាំងឡាយបានហើយ នឹងដោតពួកគេដោយ**សូលនិម្ពព្រឹក្ស** (ឈើអណ្តោតធ្វើពីដើមស្តៅ) ។ លំដាប់នោះ និម្ពរុក្ខទេវតាគិតថា «ប្រសិនបើមនុស្សទាំងឡាយមក ចាប់ចោរនេះបាន ពួកគេនឹងកាត់មែកនិម្ពព្រឹក្សនេះឯងធ្វើសូល ដោតចោរនោះពុំខាន, កាលបើយ៉ាងនេះ ដើមឈើនឹងវិនាស ណ្ហើយចុះ អញនឹងដេញចោរ នោះចេញពីទីនេះ» ។ និម្ពទេវតាកាលនឹងចរចាជាមួយនឹងចោរនោះ ទើបពោលគាថាទី ១ ថា

**ឧដ្ឋេហិ ចោរ កិំ សេសិ, កោ អត្ថោ សុបនេន តេ,**
**មា តំ គហេសុំ រាជានោ, គាមេ កិព្ពិសការកំ។**

ម្នាលចោរ អ្នកចូរក្រោកឡើង អ្នកដេកធ្វើអ្វី ប្រយោជន៍អ្វីការដេកលក់របស់អ្នក កុំឲ្យរាជបុរសទាំងឡាយ ចាប់អ្នកដែលធ្វើកម្មអាក្រក់ ក្នុងស្រុកឡើយ ។

បទថា **រាជានោ** សេចក្តីថា និម្ពរុក្ខទេវតាពោលសំដៅយករាជបុរស ។

ព្រះពោធិសត្វពោលដូច្នេះហើយ ក៏បំភ័យចោរនោះឲ្យរត់ ដោយពោលថា ដរាបណា រាជបុរសទាំងឡាយមិនទាន់ចាប់អ្នកបាន អ្នកចូរទៅក្នុងទីដទៃដរាបនោះចុះ ។

កាលចោរនោះរត់ទៅហើយ អស្សត្ថទេវតាក៏ពោលគាថាទី ២ ថា

យំ នុ ចោរំ គហេស្សន្តិ, គាមេ កិព្ពិសការកំ,
កិំ តត្ថ បុចិមន្ទស្ស, វនេ ជាតស្ស តិដ្ឋតោ។

រាជបុរសទាំងឡាយនឹងចាប់តែចោរ ដែលធ្វើកម្មអាក្រក់ ក្នុងស្រុកទេតើ ប្រយោជន៍អ្វី ដល់បុចិមន្ទទេវតា ដែលបិតនៅក្នុងព្រៃនោះ ។

និម្ពទេវតាស្តាប់ពាក្យនោះហើយ ពោលគាថាទី ៣ ថា

ន ត្វំ អស្សត្ថ ជានាសិ, មម ចោរស្ស ចន្តរំ;
ចោរំ គហេត្វា រាជានោ, គាមេ កិព្ពិសការកំ,
អប្បេន្តិ និម្ពសូលស្មិំ, តស្មិំ មេ សង្កតេ មនោ។

ម្នាលអស្សត្ថទេវតា អ្នកមិនដឹងនូវទោសនៃខ្ញុំផង នៃចោរផង ពួករាជបុរសចាប់បានចោរ អ្នកធ្វើអំពើអាក្រក់ក្នុងស្រុក ហើយដោតចោរនោះ ដោយមែកស្តៅស្រួច ខ្ញុំរង្កៀសចិត្តក្នុងហេតុនោះ ។

កាលទេវតាទាំងនោះ ចរចាឆ្លងឆ្លើយគ្នាទៅវិញទៅមកយ៉ាងនេះ ម្ចាស់ទ្រព្យមានដៃកាន់គប់ភ្លើង ក៏មកដល់ ដោយស្នាមជើងចោរ បានឃើញទីចោរដេក ក៏និយាយថា «នែគ្នាយើង ចោរទើបតែក្រោករត់ទៅអម្បាញ់មិញនេះឯង យើងចាប់ចោរមិនបានសោះ បើចាប់វាបាន មុខតែដោតវានឹងសូលនិម្ពព្រឹក្សនេះ ពុំនោះទេ នឹងព្យួរលើមែកនិម្ពព្រឹក្សនេះពុំខាន រួចហើយសឹមយើងទៅវិញ» ថាដូច្នេះហើយ ក៏នាំគ្នារត់រកទីនោះផងទីនោះផង នៅតែមិនឃើញចោរសោះ ហើយក៏នាំគ្នាត្រឡប់ទៅវិញ ។

អស្សត្ថទេវតាស្តាប់ពាក្យមនុស្សទាំងនោះ ទើបពោលគាថាទី ២ ថា

**សង្កេយ្យ សង្កិតព្វានិ, រក្ខេយ្យានាគតំ ភយំ;**
**អនាគតភយា ធីរោ, ឧភោ លោកេ អវេក្ខតិ។**

**អ្នកប្រាជ្ញគប្បីរក្សានូវហេតុ ដែលគួររង្កៀស គប្បីរក្សានូវភ័យ ដែលមិនទាន់មកដល់ អ្នកប្រាជ្ញតែងសម្លឹងមើលនូវលោកទាំងពីរ ព្រោះអនាគតភ័យ ។**

ព្រះសាស្តានាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ៖

**តទា អស្សត្ថទេវតា អានន្ទោ អហោសិ** អស្សត្ថទេវតាក្នុងកាលនោះបានមកជាអានន្ទ

**និម្ពទេវតា បន អហមេវ អហោសឹ** និម្ពទេវតាគឺតថាគតនេះឯង ។

បុចិមន្ទជាតក ចប់ ។

(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ចតុក្កនិបាត បុចិមន្ទវគ្គ បិដកលេខ ៥៨ ទំព័រ ១៩៧)

ដោយស.ដ.វ.ថ.